**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមហាផ្ទៃ**

**អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន**

លេខ : ០០១៨...អ.រ.ម

ថ្ងៃទី ០២ ខែមករា ឆ្នាំ២០១៤

**សូមគោរពជូន**

**ឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**

**កម្មវត្ថុ:** ស្តីពីការផ្សព្វផ្សាយប្រកាសអន្តរក្រសួង ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសអន្តរក្រសួង ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**យោង:** អនុក្រឹត្យលេខ៦៨អនក្រ.បក ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូនឯកឧត្តមជ្រាបថា ក្រសួងមហាផ្ទៃ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានដាក់ចេញប្រកាសអន្តរក្រសួងចំនួនពីរ រួមមាន: ប្រកាសអន្តរក្រសួង ស្តីពីការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ និងប្រកាសអន្តរក្រសួង ស្តីពីការផ្តល់រង្វាន់លើកទឹកចិត្តជូនរដ្ឋបាលថ្នាក់ក្រោមជាតិ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

អាស្រ័យហេតុនេះ អគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋានសូមផ្ញើជូនប្រកាសអន្តរក្រសួងទាំងពីរនេះ ដោយមានជូនភ្ជាប់មកជាមួយនូវតារាងឧបសម្ព័ន្ធ ដើម្បីផ្សព្វផ្សាយអនុវត្ត និងស្នើឯកឧត្តមមេត្តាជួយសម្រួលថតចម្លងបែងចែកប្រកាសទាំងពីរនេះ ជូនសាលាក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់ក្នុងដែនសមត្ថកិច្ចនៃរាជធានី ខេត្តរបស់ខ្លួន តាមការគួរ។

ក្រសួងមហាផ្ទៃនឹងធ្វើការផ្សព្វផ្សាយ និងដាក់អោយអនុវត្តនូវប្រកាសអន្តរក្រសួងទាំងពីរនេះដល់រាជធានីខេត្តក្នុងពេលឆាប់ៗខាងមុខនេះ។

សូមឯកឧត្តមមេត្តាទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

អគ្គនាយក